# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៣៦៧ ប្រក.កសក

## ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ
## របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស.៩៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន និងអនុគណៈកម្មាធិការរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣៧៥ អនក្រ.តត ចុះថ្ងៃទី១០ សីហា ឆ្នាំ២០២១ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកនៃគណៈកម្មាធិការនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងលិខិតលេខ៣៧៣៦ មស.គករ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ .**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរសេរជាអក្សរកាត់ថា "ក.ក.រ.ក" ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **នុត ច័ន្ទសុខា** | រដ្ឋលេខាធិការប្រចាំការ និងជាសមាជិក គ.ក.រ | ប្រធាន |
| ២- ឯកឧត្តម **គុយ ម៉ារិនឌី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **ចាន់ ចេស្តា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម **ណី លន់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥- លោកជំទាវ **យ៉ើ អាស៊ីគីន** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ៦- ឯកឧត្តម **ហៃ រស្មី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧- លោកជំទាវ **លី សាគីណា** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ៨- ឯកឧត្តម **ស្រី ឧុឌ្ឍី** | អគ្គលេខាធិការ | សមាជិក |
| ៩- ឯកឧត្តម **គង់ វ៉ាញ** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១០- ឯកឧត្តម **កែវ អូម៉ាលីស្ស** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១- ឯកឧត្តម **ខិន ឆាយ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១១- ឯកឧត្តម **តាន់ ផាន់ណារ៉ា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | សមាជិក |
| ១២- ឯកឧត្តម **ពុំ សុថា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល | សមាជិក |
| ១៣- ឯកឧត្តម **ហ៊ឹម អូន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ១៤- ឯកឧត្តម **ង៉ោ ប៊ុនថាន** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១៥- ឯកឧត្តម **ធន់ វឌ្ឍនា** | នាយកវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៦- ឯកឧត្តម **ហែម វីរៈ** | នាយកវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១៧- ឯកឧត្តម **ព្រំ សុម៉ានី** | ទីប្រឹក្សាក្រសួងនិងជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- លោក **មីក គឹមស្រួយ** | អគ្គលេខាធិការរង | សមាជិក |

១៩- លោក **ទី ចាន់ណា** ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិកអចិន្ត្រៃយ៍

២០- លោក **ជា ច័ន្ទវាសនា** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល សមាជិក

២១- លោកស្រី **គង់ សុធីរី** ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ សមាជិកា

២២- លោក **តុំ រ៉ា** ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម សមាជិក

២៣- លោកស្រី **ខិន សូនាថ** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិកា

២៤- លោក **គង់ ភាដ** ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម សមាជិក

២៥- លោក **ម៉ក់ ម៉ូនី** ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ សមាជិក

២៦- លោក **ម៉ៅ មិនា** ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

២៧- លោក **ឡោ ប៊ុណ្ណា** នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សមាជិក

២៨- លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សមាជិក

២៩- លោក **យៅ ទេន** ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម សមាជិក

៣០- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំង២៥ សមាជិក

៣១- លោក **អុំ សាទី** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

៣២- លោក **កោះ ឈីណ្វា** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

៣៣- លោក **ឆៃ ពិទូ** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

៣៤- លោក **ហោង ប៊ុននី** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

៣៥- លោក **រុន ទិសិទ្ធិ** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

៣៦- លោក **ប៊ុន ឡុង** ប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស លេខាធិការ

៣៧- លោក **ទ៉ែត ស៊ីណាត** ប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស លេខាធិការ

៣៨- លោក **គឹម ចាន់ដោត** អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស លេខាធិការ

៣៩- លោកស្រី **ប៊ុន សុខារ័ត្ន** អនុប្រធានការិយាល័យនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខាធិការ

**ប្រការ២ ._**

ក.ក.រ.ក មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ដឹកនាំ និងសម្របសម្រួលដំណើរការទូទៅនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កសាងយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះដើម្បីជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នដទៃ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីគាំទ្រការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមដាន ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាពនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ធ្វើរបាយការណ៍ប្រចាំខែពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និង
- ទទួលភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៣ .-**

ក.ក.រ.ក ត្រូវមានរបៀបរបបធ្វើការងារទូទៅដូចខាងក្រោម៖

- ត្រូវកំណត់របបប្រជុំប្រចាំខែ និងការប្រជុំដទៃទៀតតាមការចាំបាច់ ដើម្បីដឹកនាំ គាំទ្រ សម្របសម្រួល តាមដានត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កិច្ចប្រជុំរបស់ក្រុមការងារ ក.ក.រ.ក ត្រូវដឹកនាំដោយប្រធាន ឬអនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន
- កិច្ចប្រជុំរបស់ក្រុមការងារ ក.ក.រ.ក អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកលើសពី៥០ (ហាសិប) ភាគរយ
- ប្រធានអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានា ចូលរួមកិច្ចប្រជុំតាមការចាំបាច់ និង
- រាល់កិច្ចប្រជុំរបស់ក្រុមការងារ ត្រូវមានកំណត់ហេតុ ដែលចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។

**ប្រការ៤ .-**

ក.ក.រ.ក ប្រើប្រាស់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព។ ក.ក.រ.ក អាចទទួលមូលនិធិ ដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាតិ និងអន្តរជាតិ ព្រមទាំងប្រភពផ្សេងៗទៀត។

ក.ក.រ.ក មានសិទ្ធិប្រើរូបសញ្ញា និងត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៤ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ